**របាយការណ៍សង្ខេបរបស់**
**ឯកឧត្តម ទៀ សីហា អភិបាល នៃគណៈអភិបាលខេត្ត**
**ចូលរួមជាវាគ្មិនកិត្តិយសក្នុងសន្និសីទសារព័ត៌មាន**
**ស្តីពី "ភាពជោគជ័យក្នុងរយៈពេល៥ឆ្នាំ របស់រដ្ឋបាលខេត្តសៀមរាប"**
នៅទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣

- **សូមក្រាបថ្វាយបង្គំ ព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈដ៏ខ្ពង់ខ្ពស់**
- **សូមគោរព សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ ជាទីគោរព**!
- **សូមគោរព ឯកឧត្តម ផៃ ស៊ីផាន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និង ជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ជាទីគោរព**!
- **លោក លោកស្រី បងប្អូនអ្នកសារព័ត៌មាន និង បងប្អូនប្រជាពលរដ្ឋដែលកំពុងទស្សនាការផ្សាយផ្ទាល់ ជាទីគោរពស្រលាញ់រាប់អាន**!

ថ្ងៃនេះ ជួសមុខឱ្យក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ ប្រជាពលរដ្ឋទូទាំងខេត្ត និងក្នុងនាមខ្ញុំផ្ទាល់ ពិតជាមានក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដោយបានចូលរួមជាវាគ្មិនកិត្តិយសក្នុងសន្និសីទសារព័ត៌មាន ស្តីពី"**ភាពជោគជ័យក្នុងរយៈពេល៥ឆ្នាំ របស់រដ្ឋបាល ខេត្តសៀមរាប**" នាឱកាសដ៏ថ្លៃថ្លាវិសេសវិសាលពេលនេះ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមអនុញ្ញាតគោរពរាយការណ៍ជូនដល់អង្គសន្និសីទមេត្តាជ្រាបថា នៅក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ រដ្ឋបាលខេត្តសៀមរាបដោយមានការចូលរួមសហការពីអាជ្ញាធរគ្រប់លំដាប់ថ្នាក់ អង្គភាពពាក់ព័ន្ធ និងប្រជាពលរដ្ឋទូទាំងខេត្តបានខិតខំអនុវត្ត និងបំពេញការងារលើគ្រប់វិស័យ ដើម្បីឆ្លើយតបនូវគោលដៅអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល របស់រដ្ឋបាលខេត្តសៀមរាប ក្នុងការចូលរួមអនុវត្តនូវកម្មវិធីនយោបាយ និងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ នៃរដ្ឋសភា(ឆ្នាំ២០១៨-២០២៣)។ ឈរលើមូលដ្ឋាននេះ ខេត្តសៀមរាបនៅតែរក្សាបាននូវសុខសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខសណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម និងសម្រេចបានសមិទ្ធផលជាច្រើន រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនក្នុងខេត្តបានល្អប្រសើរតាមរយៈការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងដោយមានការយកចិត្តទុកដាក់ជាប់ជាប្រចាំរបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តសៀមរាប ដែលមាន **សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាប្រធាន** ។

ស្ថិតក្នុងប្រធានបទសន្និសីទសារព័ត៌មាននាពេលនេះ ខ្ញុំបាទនឹងធ្វើសេចក្តីរាយការណ៍ ជូនសាធារណជន និងអ្នកសារព័ត៌មាននាពេលនេះនូវ "**ភាពជោគជ័យក្នុងរយៈពេល៥ឆ្នាំ របស់រដ្ឋបាលខេត្តសៀមរាប**" និងទិសដៅអនុវត្តបន្តរបស់រដ្ឋបាលខេត្ត ដូចខាងក្រោម៖

## I-ស្ថានភាពទូទៅ ការងាររដ្ឋបាល និងការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ

ខេត្តសៀមរាបមានផ្ទៃដីសរុប ១០ ២៩៩,៤៣ គីឡូម៉ែត្រការ៉េ ចែកចេញជា ១ក្រុង និង១១ស្រុក ស្មើនឹង ១០០ឃុំ សង្កាត់ និង៩១០ភូមិ។ ខេត្តសៀមរាបមានប្រជាជន ២៥៧ ៦២៥គ្រួសារ ស្មើនឹង ១ ១៩១ ៩៩៥នាក់ ស្រី ៦០២ ១៣២នាក់ ប្រជាជនអាយុ ១៨ឆ្នាំឡើងសរុប ៧៣៨ ២២៦នាក់ ស្រី ៣៧៧ ៣៦៩នាក់ មានអត្រាកំណើនប្រជាជនប្រចាំឆ្នាំ ២,១៩ភាគរយ និងមានដង់ស៊ីតេ ១១៦នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ។ ប្រាក់ចំណូលជាមធ្យម(ផសស)សម្រាប់មនុស្សម្នាក់ស្មើនឹង ១ ៥១៧,៧ដុល្លារអាមេរិក និងផលិតផលក្នុងស្រុកសរុប(ផសស/GDP)របស់ខេត្តមាន ១ ៧៣០,៩លានដុល្លារអាមេរិក ដែលឆ្នាំ២០១៨ មានត្រឹមតែ ១ ៦២៨,១លានដុល្លារអាមេរិក។ ក្នុងអំឡុងឆ្នាំ២០២០ និងឆ្នាំ២០២១ សេដ្ឋកិច្ចខេត្ត បានរងផលប៉ះពាល់ពីវិបត្តិនៃជំងឺកូវីដ-១៩ តែយ៉ាងណាក៏ដោយរាជរដ្ឋាភិបាល បានធ្វើអន្តរាគមន៍បានទាន់ពេលវេលាតាមគ្រប់រូបភាព ដើម្បីស្តារសេដ្ឋកិច្ចខេត្ត និងជីវភាពប្រជាជន។

ក្រោមការដឹកនាំរបស់គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត យើងបានអនុវត្តកិច្ចការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈជូនប្រជាពលរដ្ឋ ភ្ញៀវទេសចរជាតិ-អន្តរជាតិ និងការការពារសន្តិសុខ សុវត្ថិភាព សម្រាប់កិច្ចប្រជុំសំខាន់ៗ ដូចជាកិច្ចប្រជុំនានាក្នុងក្របខណ្ឌអាស៊ាន និងការទទួលដំណើរទស្សនកិច្ច របស់ប្រមុខថ្នាក់ដឹកនាំប្រទេសនានា ដែលបានអញ្ជើញមកព្រះរាជាណាចក្រកម្ពុជា និងជានិច្ចកាលតែងតែមកទស្សនាតំបន់រមណីយដ្ឋានធម្មជាតិ វប្បធម៌ ប្រវត្តិសាស្ត្រក្នុងខេត្តសៀមរាប។ ចំពោះសន្តិសុខក្នុងខេត្ត សង្កេតឃើញថា បទល្មើសព្រហ្មទណ្ឌកើតឡើងចំនួន ៥២៤លើក បង្ក្រាបបាន ៩៣ភាគរយ (បទល្មើស-ឧក្រិដ្ឋ ១៦៧ករណី និងបទល្មើសមជ្ឈិម ៣៥៧ករណី) បង្ក្រាបគ្រឿងញៀនបាន ១ ៦២៩ករណី ប្រឆាំងការជួញដូរមនុស្សបង្ក្រាបបាន ៧៣ករណី និងគ្រោះថ្នាក់ចរាចរណ៍កើតឡើង ៤៤៨ករណី។ ការអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់មានសុវត្ថិភាពសម្រាប់ឆ្នាំ២០២២ មាន ៦៧ឃុំ សង្កាត់ ទទួលបានចំណាត់ថ្នាក់លេខ១ មាន២៤ឃុំ សង្កាត់ ទទួលបានចំណាត់ថ្នាក់លេខ២ និង៩ឃុំ សង្កាត់ ទទួលបានចំណាត់ថ្នាក់លេខ៣។

ចំពោះការងារទំនាក់ទំនង និងសហប្រតិបត្តិការអន្តរជាតិ ខេត្តបានចងសម្ព័ន្ធមេត្រីភាពថ្មីបន្ថែម ចំនួន១៤ ក្នុងនោះខេត្ត៧ ក្រុង៧ ដែលគិតមកទល់ពេលនេះ ខេត្តសៀមរាបបានចងសម្ព័ន្ធមេត្រីជាមួយ ខេត្ត ក្រុង សរុបចំនួន៥១ នៃបណ្តាប្រទេសជាមិត្តចំនួន១០។

## II-សមិទ្ធផលការងារក្នុងវិស័យចម្បងៗមួយចំនួនក្នុងខេត្ត

### ១-ការងារផ្តល់សេវាតាមច្រកចេញចូលតែមួយ ៖

ការបង្វិតសេវាឱ្យមកស្ថិតនៅកៀកប្រជាពលរដ្ឋ គឺជាការធ្វើកំណែទម្រង់មួយដ៏មានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ឆាប់រហ័ស និងទទួលបានការគាំទ្រខ្ពស់ពីសំណាក់បងប្អូនប្រជាពលរដ្ឋ ក្នុងចំណោមការងារកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល។ ក្នុងរយៈពេល៥ឆ្នាំនេះ សេវាច្រកចេញចូលតែមួយរបស់រដ្ឋបាលខេត្តបានទទួលការស្នើសុំសេវាលើ១៤វិស័យ សរុប ៧៦ ១៩៦សេវា ដែលមានចំណូល ២៤ ៧៦៨លានរៀល។

ចំពោះការិយាល័យច្រកចេញចូលតែមួយរបស់រដ្ឋបាលក្រុង ស្រុក គឺនៅក្រុងសៀមរាបបានអនុវត្តសាកល្បងតាំងពីឆ្នាំ២០០៥ និងបានពង្រីកអនុវត្តបន្ថែមនៅឆ្នាំ២០១៦ ចំនួន ២ស្រុក ឆ្នាំ២០១៨ ចំនួន ២ស្រុក រហូតចាប់ដំណើរការអនុវត្តបានគ្រប់១២ ក្រុង ស្រុក កាលពីដើមឆ្នាំ២០២២។ នៅថ្នាក់ក្រុង

ស្រុក បានប្រមូលសេវាមានសន្ទុះកើនឡើងយ៉ាងខ្លាំង ដែលមានហូតដល់ ៥០៤ ២២៤សេវា ស្មើនឹងទឹកប្រាក់សរុប ១៣ ៦៨៥លានរៀល។ ដោយឡែកនៅថ្នាក់រដ្ឋបាលឃុំ សង្កាត់ ក៏បានចាប់ដំណើរការអនុវត្តយន្តការច្រកចេញចូលតែមួយកាលពីពាក់កណ្តាលឆ្នាំ២០២២ ដែលរាជរដ្ឋាភិបាល នឹងបន្តអនុវត្តទៅជាសេវាច្រកចេញចូលតែមួយថ្នាក់ឃុំ សង្កាត់នាពេលដ៏ខ្លីខាងមុខ។

**២-ការងារសេវាសង្គម និងគាំពារសង្គម**

រដ្ឋបាលថ្នាក់ក្រោមជាតិ ទាំងនៅថ្នាក់ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ បានឆ្លើយតបបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ចំគោលដៅ ជាពិសេសការឆ្លុះបញ្ចាំងតាមរយៈសកម្មភាពបង្ការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ ចំពោះស្រ្តី កុមារ និងជនងាយរងគ្រោះ ទើបរាជរដ្ឋាភិបាលបានជំរុញឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តបន្ថែមទៀតការងារសេវាសង្គមចាប់ពីឆ្នាំ២០២០ កន្លងមក។

បញ្ហាស្រ្តី កុមារ និងជនងាយរងគ្រោះក្នុងខេត្ត បានទទួលការគាំពារបន្ថែមតាមរយៈគម្រោងសេវា-សង្គម ដែលមាន ១ ៤៥៩គម្រោង មានទឹកប្រាក់សរុប ៣០ ៧១៥លានរៀល។ នៅថ្នាក់ខេត្តមាន ៩៧គម្រោង ទឹកប្រាក់ ២៥ ២៣៦លានរៀល ថ្នាក់ក្រុង ស្រុក មាន ៥១គម្រោង ទឹកប្រាក់ ២៤៨លានរៀល និងថ្នាក់ឃុំ សង្កាត់ មាន ១ ៣១១គម្រោង ទឹកប្រាក់ ៥ ២៣១លានរៀល។

តាមរយៈការអនុវត្តការងារសេវាសង្គមរបស់រដ្ឋបាលខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ក្រសួងមហាផ្ទៃបានវាយតម្លៃ និងផ្តល់ចំណាត់ថ្នាក់ជ័យលាភីលេខ១ដល់រដ្ឋបាលខេត្តសៀមរាបសម្រាប់ឆ្នាំ២០២១។ ជាមួយគ្នានេះ រដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ បន្តប្តេជ្ញាចិត្តខ្ពស់ក្នុងការអនុវត្តសកម្មភាពនេះនាពេលខាងមុខឱ្យកាន់តែសកម្មបន្ថែមទៀត។

ក្នុងអំឡុងពេលវិបត្តិជំងឺកូវីដ-១៩ កម្មករនិយោជិតចំនួន ១១៤ ៩០៥នាក់ ស្រី ៥៣ ៥៨៩នាក់ (ស្មើសុំច្រើនលើក) នៃសហគ្រាសចំនួន ១៤២ ដែលមាន សណ្ឋាគារ៨៦ ផ្ទះសំណាក់១០ ភោជនីយដ្ឋាន ៣២ ភ្នាក់ងារទេសចរណ៍១៣ និងរោងចក្រកាត់ដេរ១ បានទទួលប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាលនូវទឹកប្រាក់សរុបប្រមាណ ៩,២លានដុល្លារអាមេរិក។

តាមរយៈបេឡាជាតិសន្តិសុខសង្គម រាជរដ្ឋាភិបាល បានផ្តល់មកខេត្តសៀមរាប នូវការឧបត្ថម្ភសាច់ប្រាក់ដល់កម្មករនិយោជិតជាស្រ្តីនៅពេលសម្រាលកូន(៤០ម៉ឺនរៀល) ៦ ១០៦នាក់ ស្មើនឹងទឹកប្រាក់ ២ ៤៥៩លានរៀល និងបានឧបត្ថម្ភសម្រាប់ហានិភ័យការងារ និងការឧបត្ថម្ភសម្រាប់ការថែទាំសុខភាពជូនមន្ត្រីរាជការ និវត្តន៍ជន និងកម្មករនិយោជិត ១៨៩ពាន់នាក់ ស្មើនឹងទឹកប្រាក់ ២៥ ១០៩លានរៀល។

**៣-ការងារឧបត្ថម្ភសាច់ប្រាក់គ្រួសារក្រីក្រ**

រាជរដ្ឋាភិបាល បានឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងជនងាយរងគ្រោះនានាសរុបជាទឹក-ប្រាក់ប្រមាណ ៣២៦ ២៧៤លានរៀល តាមរយៈកម្មវិធីដូចខាងក្រោម៖

- ឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ ៣ ៧០៦នាក់ និងកុមារអាយុក្រោម ២ឆ្នាំ ៩៣៤នាក់។
- ឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ(ក្រ១ ក្រ២) គ្រួសាររងគ្រោះដោយសារជំងឺកូវីដ-១៩ និងគ្រួសាររស់នៅតំបន់រម្មណីយដ្ឋានអង្គរ ដែលបានស្ម័គ្រចិត្តផ្លាស់ប្តូរការរស់នៅពីតំបន់ រមណីយដ្ឋានអង្គរទៅរស់នៅក្នុងតំបន់អភិវឌ្ឍន៍ធម្មជាតិរុនតាឯក និងតំបន់អភិវឌ្ឍន៍ពាក់ស្នែងចំនួន ៥៦ ៤៩៧គ្រួសារ។ សូមបញ្ជាក់ថា ប្រជាពលរដ្ឋដែលរស់នៅតំបន់រម្មណីយដ្ឋានអង្គរ ដែលបានស្ម័គ្រចិត្តផ្លាស់ប្តូរការរស់នៅពីតំបន់រមណីយដ្ឋានអង្គរទៅរស់នៅក្នុងតំបន់អភិវឌ្ឍន៍ធម្មជាតិរុនតាឯក និងតំបន់អភិវឌ្ឍន៍ពាក់ស្នែង ៩ ៦៨៣គ្រួសារ និងបានផ្តល់ប័ណ្ណក្រីក្រ កម្រិតក្រ១ ដែលមានរយៈពេល១០ឆ្នាំចំនួន ៨ ៩៩៥គ្រួសារ។

- ប្រជាពលរដ្ឋដែលបានសម្ភាសន៍គ្រួសាររងហានិភ័យ (សម្ពាធអតិផរណា និងគ្រោះមហន្តរាយ) ៣៨ ៩២៤គ្រួសារ ក្នុងនោះគ្រួសាររងគ្រោះដោយទឹកជំនន់ ៨ ៨៧៧គ្រួសារ។

**៤-ការងារសុខាភិបាល ៖**

មន្ទីរពេទ្យបង្អែកចំនួន ៥កន្លែង ក្នុងនោះមន្ទីរពេទ្យបង្អែកខេត្ត(កម្រិត៣) ១កន្លែង មន្ទីរពេទ្យបង្អែកស្រុកប្រតិបត្តិ(កម្រិត២) ៤កន្លែង មណ្ឌលសុខភាព ៩៣កន្លែង និងប៉ុស្តិ៍សុខភាព ២កន្លែង។ ក្នុងរយៈពេល ៥ឆ្នាំនេះ វិស័យសេវាសុខាភិបាលក្នុងខេត្ត បានអភិវឌ្ឍដើម្បីឆ្លើយតបនឹងតម្រូវការសេវារួមមាន ការសាងសង់មណ្ឌលសុខភាពបន្ថែម ៣កន្លែង ការជួសជុលអគារមណ្ឌលសុខភាព ១៥កន្លែង ការអភិវឌ្ឍន៍មន្ទីរពេទ្យបង្អែកពីកម្រិត១ ទៅជាកម្រិត២ ចំនួន ២កន្លែង និងការជួសជុល អគារមន្ទីរពិសោធន៍ កន្លែងផលិតអុកស៊ីសែន អគារវះកាត់ និងអគារសម្រាកព្យាបាលជាដើម។ ជាមួយគ្នានេះ មន្ទីរពេទ្យបង្អែកខេត្ត កំពុងដំណើរការសាងសង់អគារ និងបំពាក់បរិក្ខារ-សម្ភារសរុបទឹកប្រាក់ ១៩,៨លានដុល្លារ ជាជំនួយឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុន តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA) ដែលគ្រោងបញ្ចប់នៅខែតុលា ឆ្នាំ២០២៣នេះ។

ការផ្តល់សេវាសុខាភិបាលពិនិត្យពិគ្រោះជម្ងឺក្រៅសរុបនៅមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកចំនួនប្រមាណ ៥លាននាក់ ការសម្រាកព្យាបាលនៅមន្ទីរពេទ្យប្រមាណ ២៣ម៉ឺននាក់ ការសម្រាលកូនប្រមាណ ៦ម៉ឺន៦ពាន់នាក់។

តាមរយៈកម្មវិធីមូលនិធិសមធម៌ អ្នកជំងឺដែលមានប័ណ្ណក្រីក្រ និងអ្នកត្រូវបានសម្ភាសន៍ចាត់ទុកជាជនក្រីក្រមានចំនួន ១លាន៦០ម៉ឺនករណី ដែលមានទឹកប្រាក់ ១៧ ៩៧២លានរៀល សម្រាប់ការលើកលែងថ្លៃពិនិត្យពិគ្រោះព្យាបាលជំងឺ ការហូបចុក និងថ្លៃធ្វើដំណើរ ជាដើម។

ចំពោះការបង្ការ ទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលបានផ្តល់ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនប្រជាជនដោយឥតគិតថ្លៃបានប្រមាណ ៩៨ម៉ឺននាក់ ស្មើនឹង ៩៦ភាគរយនៃប្រជាជនសរុប។ ចំពោះអ្នកជំងឺកូវីដ-១៩ ប្រមាណ ២ម៉ឺន២ពាន់នាក់ បានទទួលសេវាព្យាបាលដោយគិតថ្លៃ និងអ្នកមរណភាពចំនួន ៣២៦នាក់ ក៏ទទួលថវិកាជួយសម្រាប់ការរៀបចំពិធីបូជាទៅតាមប្រពៃណី។

ក្រៅពីនេះ ខេត្តក៏មានមន្ទីរពេទ្យកុមារចំនួន ២កន្លែង ដែលទទួលបានថវិកាគាំទ្រពីរាជរដ្ឋាភិបាល និងសប្បុរសជនជាតិ-អន្តរជាតិ។

**៥-វិស័យសាធារណការ ផ្លូវលំជនបទ និងការអភិវឌ្ឍទីក្រុង៖**

ខេត្តសៀមរាប បានបន្តស្តារហេដ្ឋារចនាសម្ព័ន្ធទាំងនៅក្នុងទីក្រុង និងជនបទ ដោយផ្តោតសំខាន់លើការសាងសង់ ជួសជុល ថែទាំងបណ្តាញផ្លូវថ្នល់នៅក្នុងទីក្រុង ពីទីប្រជុំជនទៅជនបទ និងទីជនបទដើម្បីចូលរួមចំណែកលើកស្ទួយជីវភាពប្រជាជន និងជំរុញកំណើនសេដ្ឋកិច្ចខេត្ត។ ក្នុងរយៈពេល ៥ឆ្នាំនេះ ខេត្តបានជួលជុលប្រវែង ៤ ៦៧៧គីឡូម៉ែត្រ និងបានសាងសង់ផ្លូវសរុប មានប្រវែង ៦ ០៦៦គីឡូម៉ែត្រដោយប្រើប្រាស់ថវិការបស់រដ្ឋបាលខេត្ត មន្ទីរសាធារណការ និងដឹកជញ្ជូន មន្ទីរអភិវឌ្ឍន៍ជនបទ រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់។

ដើម្បីបង្កើនសមត្ថភាពរំដោះទឹកកកខ្វក់ ខេត្តបានទទួលជំនួយដាក់លូទឹកកខ្វក់លើផ្លូវស៊ីវត្ថាប្រវែង ៣,៧គីឡូម៉ែត្រ ក្រុងសៀមរាប និងបានបញ្ចប់ការស្ថាបនាកាលពីឆ្នាំ២០២១។ គម្រោងនេះចំណាយថវិកា ១២,៩៥លានដុល្លារ ដែលជាឥណទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ីក្រោមរូបភាពកិច្ចសហប្រតិបត្តិការ

និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាល។ ក្រោមកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ពីសាធារណរដ្ឋបារាំង ក្រោមជំនួយហិរញ្ញវត្ថុ ១,៧លានអឺរ៉ូ និងបច្ចេកទេសរបស់សមាគមនិយមនិយាយភាសាបារាំង(AIMF) ទីភ្នាក់ងារទឹកសែនណកម៉ង់ឌី (AESN) និងសហជីពសម្រាប់ប្រព័ន្ធអនាម័យ(SiAAP) ក្នុងការផលិតជីសរីរាង្គលក់ក្នុងតម្លៃទាបសម្រាប់ ប្រជាកសិករមានឱកាសប្រកួតប្រជែងទីផ្សារកសិកម្ម ហើយបច្ចុប្បន្នរោងចក្រត្រូវបានសាងសង់រួចរាល់ និងគ្រោងដំណើរការផលិតជីក្នុងពេលឆាប់ៗខាងមុខនេះ ដែលមានសមត្ថភាពផលិតបានយ៉ាងតិច ៥តោនក្នុង១ខែ។

បន្ថែមលើសនេះ អ្វីដែលមិនអាចបំភ្លេចបានសម្រាប់ប្រជាជននៅក្នុងខេត្តសៀមរាបនោះគឺចំណងដៃផ្លូវ ៣៨ខ្សែ នៅក្នុងក្រុងសៀមរាប ដែលរាជរដ្ឋាភិបាលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់ចំណងដៃសាងសង់ផ្លូវ ៣៨ខ្សែ នៅក្នុងក្រុងសៀមរាប មានប្រវែងប្រមាណ ១០៦,៥គីឡូម៉ែត្រ ដែលចំណាយថវិកាប្រមាណ ១៥៣លានដុល្លារ។ គម្រោងនេះបន្ថែមដោយមានការរៀបចំសោភ័ណភាពដងស្ទឹងសៀមរាប ការស្តារ និងសាងសង់បណ្តាញលូទឹកភ្លៀង លូទឹកកខ្វក់ ការរៀបចំចំណតនៅតាមដងផ្លូវជាតិលេខ៦ ការបំពាក់កាមេរ៉ាសុវត្ថិភាព ភ្លើងសញ្ញាចរាចរណ៍ និងបំពាក់អំពូលបំភ្លឺសាធារណៈសន្សំសំចៃថាមពល(LED)និងភ្ជាប់ដោយប្រព័ន្ធបញ្ជាស្វ័យប្រវត្តិមានចំនួន ៤ ៣៨៩អំពូល បន្ថែមលើអំពូលដែលមានស្រាប់ចំនួន ៩ ៦១៦អំពូល ដែលធ្វើឱ្យតាមដងផ្លូវសំខាន់ៗក្នុងក្រុងសៀមរាបត្រូវបានបំភ្លឺ។

ស្របជាមួយគ្នានេះ ខេត្តក៏បានរៀបចំសួនច្បារមាត់ស្ទឹងខាងជើងស្ពានថ្មព្រះរាជដំណាក់ និងបំពាក់នូវឧបករណ៍ហាត់ប្រាណ ការរៀបចំរង្វង់មូលផ្ការំដួល ការរៀបចំសួនច្បារមុខសាលាគុរុកោសល្យហើយជានិច្ចកាលការរៀបចំតុបតែងលំអរតាមដងស្ទឹងនៅរាល់ពិធីបុណ្យជាតិ-អន្តរជាតិ។ អ្វីដែលកាន់តែទាក់-ទាញបន្ថែមទៀតនោះ គឺសួនច្បារមុខព្រះរាជដំណាក់ត្រូវកែលម្អយ៉ាងស្រស់ស្អាត និងតម្លើងរូបសំណាកបុព្វបុរសជាមេទ័ពខ្មែរកាលពីជំនាន់មុនចំនួន១២រូប ដែលត្រូវបានរៀបចំដោយក្រសួងព្រះបរមរាជវាំង។

ដើម្បីឱ្យសក្តិសមជាសមាជិកទីក្រុងឆ្លាតវៃអាស៊ាន ក្រុងសៀមរាបត្រូវបានអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធការគ្រប់គ្រងកាកសំណល់រឹង-រាវ ការរៀបចំសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ។ កន្លងមកចំពោះការរៀបចំទីក្រុងឆ្លាតវៃ ខេត្តក៏ទទួលបានជំនួយបច្ចេកទេសពីក្រសួងដែនដី ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងទេសចរណ៍របស់ប្រទេសជប៉ុន(MLIT) និងកិច្ចសហប្រតិបត្តិការបច្ចេកទេសពីទីភ្នាក់ងារសហប្រតិ-បត្តិការអន្តរជាតិជប៉ុន(JICA) ដែលតាមរយៈនេះ ក្រុងសៀមរាប នឹងរៀបចំបញ្ចប់ផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃ ក្នុងខេត្តសៀមរាបត្រឹមខែមីនា ឆ្នាំ២០២៣។ ការណ៍នេះ ក៏មានការអនុវត្តសាកល្បង ០៦គម្រោងរួមមាន គម្រោងត្រួតពិនិត្យការចតយានយន្តខុសច្បាប់ គម្រោងកែលម្អការប្រមូលសំរាម គម្រោងបំប្លែងឯកសារឬព័ត៌មានទេសចរណ៍ឱ្យទៅជាទិន្នន័យឌីជីថល គម្រោងប្រព័ន្ធតាមដានលំហូរឯកសារផ្ទៃក្នុង គម្រោងតាមដានបរិស្ថានទីក្រុងដោយប្រើប្រាស់Sensor និងគម្រោងកិច្ចសហការរវាងរដ្ឋ និងឯកជនក្នុងវិស័យទេសចរណ៍។ គម្រោងទាំងនោះផ្តោតលើវិស័យសំខាន់ៗ ចំនួន៤ រួមមាន ទេសចរណ៍ឆ្លាតវៃ(Smart Tourism) ប្រព័ន្ធចល័តឆ្លាតវៃ(Smart Mobility) សន្តិសុខឆ្លាតវៃ(Smart Security) និងការគ្រប់គ្រងកាកសំណល់ឆ្លាតវៃ(Smart Waste Management)។

រាជរដ្ឋាភិបាល បានអនុញ្ញាតឱ្យក្រុមហ៊ុនវិនិយោគអាកាសយានដ្ឋានអន្តរជាតិអង្គរ (Angkor International Airport Investment Cambodia Co.,Ltd) ហៅកាត់ AIAI សាងសង់ព្រលានយន្ត-ហោះថ្មី ស្ថិតនៅឃុំពពេល ស្រុកសូទ្រនិគម លើផ្ទៃដីប្រមាណ ៧៥០ហិកតា មានទុនវិនិយោគប្រមាណ

៩០០លានដុល្លារអាមេរិក សម្រាប់សាងសង់ព្រលានយន្តហោះសៀមរាប-អង្គរ គិតត្រឹមថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ សម្រេចបានប្រមាណ ៧៥ភាគរយ ហើយគ្រោងនឹងបញ្ចប់ការសាងសង់ និងបើកទទួលការចុះចតនៅខែតុលា ឆ្នាំ២០២៣ ខាងមុខ។

គម្រោងស្តារស្ទឹងសៀមរាបដំណាក់កាលទី២ ប្រវែង ៤ ៥៣៣ម៉ែត្រ ចាប់ពីស្ពានក្រវ៉ាត់ក្រុង ដល់ភូមិអារញ្ញ ដើម្បីបញ្ចៀសទឹកជំនន់ និងរៀបចំសោភ័ណភាព ចំណាយទឹកប្រាក់ ១៣,៣០៣លានដុល្លារអាមេរិក ក្រោមជំនួយហិរញ្ញប្បទានរបស់សាធារណរដ្ឋកូរ៉េ ដែលបានចាប់ដំណើរការស្តារកាលពីខែឧសភា ឆ្នាំ២០២២។

**៦-វិស័យទេសចរណ៍ ៖**

វិស័យទេសចរណ៍ បានរួមចំណែកយ៉ាងសំខាន់ជាមួយវិស័យកសិកម្ម សម្រាប់ចូលរួមចំណែកលើកស្ទួយជីវភាពប្រជាជន និងសេដ្ឋកិច្ចខេត្តទាំងមូល។ ខេត្តមានសណ្ឋាគារ ២៣៧ទីតាំង ស្មើនឹង ១៥ ២២២បន្ទប់ ផ្ទះភ្ញៀវ ២៨៣ទីតាំង ភោជនីយដ្ឋាន ២៣៩កន្លែង ហាងម៉ាហ្សា ៦៩កន្លែង មគ្គុទេសក៍ទេសចរណ៍ ៥ ១១៧នាក់ និងទីភ្នាក់ងារទេសចរណ៍ ៣២១។ ភ្ញៀវទេសចរណ៍កាលពីឆ្នាំ ២០១៨ មានភ្ញៀវទេសចរសរុបចំនួន ៥,៧លាននាក់ ក្នុងនោះភ្ញៀវអន្តរជាតិចំនួន ២,៥លាននាក់ ប៉ុន្តែដោយសារវិបត្តិសកលនៃជំងឺកូវីដ-១៩ បានជះឥទ្ធិពលយ៉ាងខ្លាំងចំពោះវិស័យទេសចរណ៍ខេត្ត ចាប់ពីឆ្នាំ ២០១៩ ដែលសេវាកម្មទេសចរណ៍ត្រូវបានបិទ និងផ្អាក ស្ទើរតែទាំងស្រុង ហើយទើបនឹងបានចាប់ផ្តើមមានកំណើនភ្ញៀវទេសចរប្រសើរឡើងវិញនៅឆ្នាំ២០២២។

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ប្រមុខរាជរដ្ឋាភិបាល លើការងារបង្ការទប់ស្កាត់ជំងឺកូវីដ-១៩ ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនប្រជាជនក្នុងខេត្តសៀមរាប ស្របពេលវិបត្តិជំងឺកូវីដ-១៩សកលថមថយផងនោះ ភ្ញៀវទេសចរមកទស្សនាខេត្តសៀមរាបមានសន្ទុះកើនឡើងដែលនៅឆ្នាំ២០២២ មានភ្ញៀវទេសចរចំនួន ២ ៦៩២ ៤២៣នាក់ ក្នុងនោះភ្ញៀវបរទេសចំនួន ២៨៧ ៤៥៤នាក់។

ខេត្តបានចុះត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ និងស្តង់ដារអប្បបរមា (SOP) ស្របតាមគន្លងប្រក្រតីភាពថ្មីនៅទីតាំងអាជីវកម្មទេសចរណ៍ចំនួន ២៨៨កន្លែង។

ក្រៅពីការឧបត្ថម្ភសាច់ប្រាក់ជូនកម្មករនិយោជិតព្យួរកិច្ចសន្យាការងារ ដែលស្នើដោយសហគ្រាស **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានប្រកាសលើកលែង និងអនុគ្រោះពន្ធដល់សហគ្រាស ក្នុងវិស័យ-ទេសចរណ៍ ដោយគិតចាប់ពី ខែកុម្ភៈ ឆ្នាំ២០២០ នៅបន្តដល់ខែមីនា ឆ្នាំ២០២៣។

ក្រៅពីរមណីយដ្ឋានប្រវត្តិសាស្ត្រ និងប្រាសាទបុរាណ ខេត្តក៏មានរមណីយដ្ឋានធម្មជាតិ និងកែច្នៃជាច្រើនកន្លែងដូចជា រមណីយដ្ឋានធម្មជាតិចង្ក្រានរយដែលរដ្ឋបាលខេត្ត បានគាំទ្រដល់សហគ្រិនវ័យក្មេងកម្ពុជាខេត្តសៀមរាប និងសហគមន៍ រមណីយដ្ឋានសួនពិព័រណ៍ត្រីទឹកសាប ទឹកប្រៃ និងសត្វជាច្រើនប្រភេទរបស់ក្រុមហ៊ុន អង្គរវ៉ាយឌ៍ឡាយហ្វ៍ និងអឺឃ្វារៀម (Angkor Wildlife & Aquarium) និងរមណីយដ្ឋាន សេវាកម្មស្នាក់នៅ និងអាហារដ្ឋានមានលក្ខណៈដាច់ដោយឡែកជាច្រើនត្រូវបានបង្កើតឡើង បានរួមចំណែកលើកស្ទួយវិស័យទេសចរណ៍ខេត្ត។

ផ្តែកលើសក្តានុពលខេត្ត ដែលជាខេត្តទេសចរណ៍ធម្មជាតិ វប្បធម៌ និងប្រវត្តិសាស្ត្រ ការរៀបចំកែលម្អសោភ័ណភាពទីក្រុង សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ការរៀបចំព្រឹត្តិការណ៍កំសាន្តសប្បាយប្រកបដោយភាពទាក់ទាញ និងការចូលរួមរបស់បងប្អូនប្រជាពលរដ្ឋក្នុងខេត្ត បានធ្វើឱ្យខេត្តទទួលបានចំណាត់ថ្នាក់ និងការគាំទ្ររួមមាន៖

- ក្រុងសៀមរាបទទួលបានពានរង្វាន់ជ័យលាភីទីក្រុងទេសចរណ៍ស្អាតអាស៊ានលើកទី២ នៅឆ្នាំ ២០១៨ និងលើកទី៣ នៅឆ្នាំ២០២២
- ក្រុងសៀមរាប ទទួលបានជ័យលាភី ផ្ការំដួល ៣ទងចំនួន ៣លើកជាប់គ្នា គឺនៅឆ្នាំ២០១៥ ឆ្នាំ២០១៨ និងឆ្នាំ២០២២ ក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត
- ពានរង្វាន់ជ័យលាភីជាទីក្រុងដែលមានពិធីបុណ្យចូលឆ្នាំសកលល្អជាងគេ(Best Countdown City Of The Year)ចំនួន ៣លើក ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០១៩ ចំណាត់ថ្នាក់លេខ២ ប្រចាំឆ្នាំ២០២១ និងចំណាត់ថ្នាក់លេខ៣ ឆ្នាំ២០២២
- "ភូមិវត្តបូព៌" ក្នុងសង្កាត់សាលាកំរើក ក្រុងសៀមរាប ជាប់លំដាប់លេខ៣ ក្នុងចំណោមទីតាំងដ៏សែនមនោរម្យទាំង៥១ លើពិភពលោក តាមរយៈគេហទំព័រ Time Out និងបានផ្សព្វផ្សាយដោយ CNN។

**៧-វិស័យកសិកម្ម៖**

ខេត្តមានប្រជាជនប្រកបរបរកសិកម្មចំនួន ៣៥៣ ១៦៨គ្រួសារ ស្មើនឹង ៦៧,៦៨ភាគរយ ធៀបនឹងអ្នកមានមុខរបរសរុបក្នុងខេត្ត។ ផ្ទៃដីដាំដំណាំកសិកម្មមាន ២៩៦ ៣០៧ហិកតា ក្នុងនោះ ផ្ទៃដីដំណាំស្រូវ ២០៥ ២៣១ហិកតា ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្ម រយៈពេលខ្លី (ដំណាំរួមផ្សំ) ៥០ ៧៤៨ហិកតា និងផ្ទៃដីដំណាំឧស្សាហកម្មរយៈពេលវែង និងដំណាំឈើហូប ផ្ទៃចំនួន ៤០ ៣២៨ហិកតា។ បរិមាណផលស្រូវប្រចាំឆ្នាំចន្លោះពី ៥៣៤ពាន់តោន ទៅ ៦០៨ពាន់ តោន ដែលបរិមាណនេះធានាបាននូវសន្តិសុខស្បៀងសម្រាប់ប្រើប្រាស់ក្នុងខេត្ត និងមានសល់ជាស្រូវសម្រាប់នាំចេញប្រចាំឆ្នាំក្នុងរង្វង់ ២៥ម៉ឺនតោន។ ទិន្នផលស្រូវពីមួយឆ្នាំទៅមួយឆ្នាំកើនពី ២,៦៤៦ តោន/ហិកតា ក្នុងឆ្នាំ២០១៨ និងកើនដល់ ២,៧៨០តោន/ហិកតា ក្នុងឆ្នាំ២០២២។

ដំណាំសាកវប្បកម្ម មានដំណាំបន្លែគ្រប់ប្រភេទ ដំណាំពោតស និងដំណាំឧស្សាហកម្មរយៈពេលខ្លី មានដំណាំអំពៅ ដំឡូងមីជាដើម បានរួមចំណែកផ្គត់ផ្គង់តម្រូវការទីផ្សារក្នុងខេត្ត ប្រើប្រាស់ជាស្បៀងអាហារូបត្ថម្ភ និងបង្កើនប្រាក់ចំណូលក្នុងគ្រួសារ។ ដោយមានអំណោយផលពីធម្មជាតិ និងមានតម្រូវការទីផ្សារ ធ្វើឱ្យបរិមាណផលដំណាំរួមផ្សំមានការកើនឡើងបានប្រមាណ ៣១,៩៥% ស្មើនឹង ៥៤១ ០១៤ តោន នៅក្នុងឆ្នាំ២០១៨ និងកើនដល់ ៧១៣ ៨៨៥តោន នៅក្នុងឆ្នាំ២០២២ បើទោះបីឆ្នាំ២០២២នេះ ទឹកជំនន់ទឹកភ្លៀងរដូវវស្សាបណ្តាលឱ្យខូចខាតផលដំណាំមួយចំនួនក៏ដោយ។

**៨-ការងារប្រព័ន្ធធារាសាស្ត្រ ៖**

ទូទាំងខេត្ត មានប្រព័ន្ធធារាសាស្ត្រ តូច ធំ និងមធ្យមសរុបចំនួន ១៤៥ប្រព័ន្ធធារាសាស្ត្រ ដែលបានផ្តល់ការស្រោចស្រពលើផ្ទៃដីកសិកម្មបានចំនួន ៦១,៤៥ភាគរយ ក្នុងនោះរដូវវស្សាបានចំនួន ៥៨,១៧ភាគរយ និងនៅរដូវប្រាំងបានចំនួន ៨៦,២២ ភាគរយ។

សម្រាប់រយៈពេល ៥ឆ្នាំនេះ ខេត្តបានសាងសង់សំណង់ធារាសាស្ត្រចំនួន ៤៦២សំណង់ ជួសជុលទំនប់ ៧៨គីឡូម៉ែត្រ ជួសជុលប្រឡាយ ២៧៣គីឡូម៉ែត្រ ជួសជុលសំណង់ ១០កន្លែង ជួសជុលថែទាំជាប្រចាំ ៣៨កន្លែង អន្តរាគមន៍បូមទឹកសង្គ្រោះស្រែប្រាំងនិងវស្សា ៨ ០៩៣ហិកតា។

**៩-ការងារពាណិជ្ជកម្ម និងឧស្សាហកម្ម**

ចំពោះសកម្មភាពការងារពាណិជ្ជកម្ម ក្នុងរយៈពេលប្រាំឆ្នាំកន្លងមកនេះ របស់មន្ទីរពាណិជ្ជកម្មខេត្តមាន ការចុះបញ្ជីពាណិជ្ជកម្មសរុបមានចំនួន ៣៦៣០ អង្គភាពអាជីវកម្ម ការចុះត្រួតពិនិត្យប្រេង

ឥន្ទនៈ និងទំនិញនៅតាមទីផ្សារ ការត្រួតពិនិត្យអាល់កុល ក្នុងកំឡុងពេលរីករាលដាលកូវីដ-១៩ មានចំនួន ៩២០ទីតាំង ដកហូតផលិតខូចគុណភាពបាន ៦តោន។ បានសម្របសម្រួលការចុះកិច្ចសន្យាទិញ-លក់ មាន់ស្រែ បន្លែ និងស្រូវបានចំនួន៥២៧ កិច្ចសន្យា ស្មើនឹង ១៧ពាន់តោន ដែលមានតំលៃជាទឹកប្រាក់ចំនួនប្រមាណជា ២៦ពាន់លានរៀល ឬ ៦,៥លានដុល្លារអាមេរិច ដល់កសិករ ក្នុងគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច ដែលមានកសិករចូលរួមចំនួន ៣ ០៤៧ គ្រួសារ។ ទីតាំងសិប្បកម្មធុនតូច សហគ្រាសធុនតូចនិងមធ្យម និងរោងចក្រក្នុងខេត្តសរុបមានចំនួន ៣ ៨១៦កន្លែង កើនឡើង ២២២កន្លែង ក្នុងនោះស្ថិតិសិប្បកម្មដែលមានទុនវិនិយោគទឹកប្រាក់ក្រោម ៥ម៉ឺនដុល្លារអាមេរិក មាន ៣៦១៧កន្លែង សហគ្រាសធុនតូច និងមធ្យម ១៣៥កន្លែង និងរោងចក្រ ៥កន្លែង។

**១០-ការងារទឹកស្អាត និងអនាម័យ**

ការងារផ្គត់ផ្គង់ទឹកស្អាតក្នុងក្រុងសៀមរាប អនុវត្តដោយរដ្ឋាករទឹកស្វយ័តសៀមរាប បានផ្គត់ផ្គង់ទឹកស្អាតដល់អតិថិជន ១៨ ៥៨៨ បរិមាណផ្គត់ផ្គង់ទឹកប្រចាំឆ្នាំចន្លោះពី ៥ ទៅ ៧លានម៉ែត្រគូប និងការផ្គត់ផ្គង់ទឹកស្អាតនៅទីរួមស្រុកទាំង៦ អនុវត្តដោយសេវាករ ៨ក្រុមហ៊ុន បានផ្គត់ផ្គង់ទឹកស្អាតដល់អតិថិជន ១២ ៧៨២ បរិមាណទឹកប្រចាំឆ្នាំចន្លោះពី ៧៥ម៉ឺន ទៅ ១លានម៉ែត្រគូប ដូចនេះការផ្គត់ផ្គង់ទឹកស្អាតជូនអតិថិជនសរុបមានចំនួន ៣១ ៣៧០។

រដ្ឋាករទឹកស្វយ័តសៀមរាបបានបង្កើនលទ្ធភាពផលិតទឹកស្អាតពី ១ម៉ឺន៥ពាន់ម៉ែត្រគូបក្នុងមួយថ្ងៃមក៣ម៉ឺនម៉ែត្រគូបក្នុងមួយថ្ងៃ ចាប់ពីឆ្នាំ២០១៩ តាមរយៈការសាងសង់រោងចក្រប្រព្រឹត្តិកម្មបន្ថែម ២កន្លែង និងការតបណ្តាញមេនិងបណ្តាញចែកចាយ ដែលជាជំនួយឥតសំណងរបស់JICA និងឥណទានរបស់ទីភ្នាក់ងារបារាំងដើម្បីអភិវឌ្ឍ(AFD) ព្រមទាំងបានតបណ្តាញប្រវែង ១០០គីឡូម៉ែត្រ និងបានភ្ជាប់បណ្តាញចូលផ្ទះបន្ថែម៥០០០តំណ ដែលជាកម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី(ADB)។ ដើម្បីបំពេញតម្រូវការទឹកស្អាតនៅក្នុងក្រុងសៀមរាប JICAបានផ្តល់ឥណទានអនុវត្តគម្រោងសាងសង់រោងចក្រប្រព្រឹត្តិកម្មទឹកស្អាតមួយកន្លែងទៀត ស្ថិតនៅសង្កាត់ជ្រាវ ក្រុងសៀមរាប ដែលមានសមត្ថភាពផលិតទឹកស្អាត ៦ម៉ឺនម៉ែត្រគូបក្នុងមួយថ្ងៃ ដោយយកប្រភពទឹកចេញពីបឹងទន្លេសាប និងការសាងសង់បណ្តាញមេនិងបណ្តាញចែកចាយប្រវែង ២៤៧គីឡូម៉ែត្រ ដែលគ្រោងនឹងបញ្ចប់ និងដាក់ឱ្យដំណើរការនៅដំណាច់ខែមីនាឆ្នាំ២០២៣។ សមត្ថភាពផលិតទឹកស្អាតរបស់រដ្ឋាករទឹកស្វយ័តសៀមរាប នឹងកើនឡើងរហូតដល់៩ម៉ឺនម៉ែត្រគូប ដែលគ្របដណ្តប់លើតម្រូវការទឹកស្អាតក្នុងក្រុងសៀមរាបទាំងមូលរហូតដល់ឆ្នាំ២០៣២។

ជាមួយនឹងការយកចិត្តទុកដាក់ដល់ប្រជាពលរដ្ឋស្ម័គ្រចិត្តរុះរើចេញ ពីតំបន់រមណីយដ្ឋានអង្គរទៅរស់តំបន់អភិវឌ្ឍន៍រុនតាឯក និងពាក់ស្នែង រាជរដ្ឋាភិបាល បានផ្តល់ការតបណ្តាញទឹកស្អាតពីក្នុងក្រុងសៀមរាបទៅតំបន់ទាំង២នេះ គ្រោងនឹងបញ្ចប់នៅខែកក្កដា ឆ្នាំ២០២៣ ដោយមានបណ្តាញមេ ៦៩គីឡូម៉ែត្រ និងបណ្តាញចែកចាយតាមខ្នងផ្ទះ។

ដោយឡែក វិស័យផ្គត់ផ្គង់ទឹកជនបទ បានសាងសង់ និងផ្តល់អណ្តូងស្នប់អាហ្វ្រីដេស ចំនួន ៥៧២ អណ្តូង ពាងត្រងទឹកភ្លៀងចំនួន ២៤ ៧៧៣ពាង ស្តារនិងជីកស្រះសហគមន៍ ២២ស្រះ អាងបេតុងត្រងទឹកភ្លៀងចំណុះ១០ម៉ែត្រគូប ២៤អាង ស្ថានីយ៍ចម្រោះ និងបណ្តាញចែកចាយទឹកស្អាត ១ស្ថានីយ៍។ ដូចនេះការផ្គត់ផ្គង់ទឹកស្អាតក្នុងទីក្រុង ទីប្រជុំជន និងជនបទមានគ្រប់ដណ្តប់បាន ៧៦ភាគរយ គិតជាគ្រួសារមាន១៩៥ ៧១៩គ្រួសារ។ ខេត្តបានផ្តល់សម្ភារៈបង្គន់អនាម័យ ១១២៥បង្គន់ បង្គន់សាធារណៈ ៣៦កន្លែង ទន្ទឹមគ្នានេះក្រុមការងារបានចុះអនុវត្តកម្មវិធីជំរុញសហគមន៍ដឹកនាំអនាម័យនៅមូលដ្ឋាន

(CLTS) ជាលទ្ធផលសម្រេចបានការបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល(ODF) ដែលមានអ្នកទទួលផលចំនួន ២១១ ៧៨៥ខ្នងផ្ទះ ស្មើ ៨៤.៥៣%ក្នុងខេត្តសៀមរាប។

**១១-ការងារអគ្គិសនី ៖**

គិតត្រឹមឆ្នាំ២០២២ ការផ្គត់ផ្គង់អគ្គីសនីក្នុងខេត្តសៀមរាប មានសេវាករអគ្គិសនីចំនួន ២២ រាប់បញ្ចូលទាំងអគ្គិសនីសៀមរាប គ្របដណ្តប់ការចែកចាយបានចំនួន ៩៨,៨១% នៃភូមិទូទាំងខេត្ត ដែលគ្រួសារមានអគ្គិសនីប្រើប្រាស់ ២១៣ ១១៨គ្រួសារ។ ប្រភពផ្គត់ផ្គង់អគ្គិសនី មាន២អនុស្ថានីយ៍ ដែលមានអានុភាព ២២៥មេកាវ៉ាត់ និងម៉ាស៊ីនត្រៀមបម្រុងអានុភាព ១០មេកាវ៉ាត់ ដើម្បីបំពេញតម្រូវការប្រើប្រាស់ប្រចាំឆ្នាំក្នុងខេត្តមានចន្លោះពី ៤៧០ជីកាវ៉ាត់ម៉ោង ទៅ ៦៥០ជីកាវ៉ាត់ម៉ោង។ ក្នុងរយៈពេល៥ឆ្នាំនេះ បានសាងសង់អនុស្ថានីយ៍បន្ថែម១ទីតាំង ទំហំ១៥០មេកាវ៉ាត់ បានអូសបណ្តាញតង់ស្យុងមធ្យម(MV)ប្រវែង១ ៦៣០គីឡូម៉ែត្រ បានអូសបណ្តាញតង់ស្យុងទាប(LV)ទាំងក្រោមដី និងលើអាកាសប្រវែង១ ៦១៨គីឡូម៉ែត្រ និងតម្លើងត្រង់ស្វូចែកចាយបាន ១ ៣៣៦ទីតាំង។

ក្រុមការងាររបស់អគ្គិសនីសៀមរាប ក៏បានអនុវត្តគម្រោងសាងសង់ខ្សែបណ្តាញអគ្គិសនីនៅតំបន់អភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯក និងពាក់ស្នែង សម្រាប់បំពេញតម្រូវការប្រើប្រាស់ដល់បងប្អូនប្រជាពលរដ្ឋស្ម័គ្រចិត្តរុះរើចេញពីតំបន់រមណីយដ្ឋានអង្គរ។

**១២-ការងាររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៖**

ការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធរយៈពេល៥ឆ្នាំ ខេត្តបានចេញប័ណ្ណកម្មសិទ្ធបានចំនួនសរុប ៤៨ ៤៧៦ ប័ណ្ណ ដែលអនុវត្តនៅក្រុង-ស្រុកចំនួន០៦ លើក្រុង-ស្រុកទាំង ១២ទូទាំងខេត្ត។ គិតតាំងពីចាប់ផ្តើមអនុវត្តឆ្នាំ២០០៤ មកទល់ពេលនេះ យើងបានចុះបញ្ជីបានចំនួន ១៥២ ២៩១ក្បាលដី នៃភូមិ១៦៧ភូមិ បានចេញប័ណ្ណ ៨១ ៦៤៤ប័ណ្ណ នៃភូមិ ៨៧ភូមិ នៅសល់ ៧០ ៦៤៧ក្បាលដី ដោយសារព្រំប្រទល់កំណត់តំបន់១ និងតំបន់២ នៃអាង្គាធរបឹងទន្លេសាប មិនទាន់ច្បាស់លាស់ និងមួយចំនួនទៀតដោយសារក្រោយបិទផ្សាយ មានបណ្តឹងតវ៉ានិងមិនទាន់ដោះស្រាយរួច។

ការងារដីសម្បទានសង្គម ខេត្តបានចុះបញ្ជីដីធ្លីជូនប្រជាពលរដ្ឋ(សម្បទាននិក) នៅភូមិកំព្រំ ឃុំយុនរាម ស្រុកបន្ទាយស្រី បានចំនួន ១៥០គ្រួសារ។ ប្រជាពលរដ្ឋរស់នៅតំបន់មិនរៀបរយលើដីចំណីផ្លូវ និងប្រឡាយប៉ះពាល់ដល់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធខេត្តចំនួន ៧៥គ្រួសារ ទទួលបានដីសម្បទានសង្គម និងលំនៅឋាន។

ការងាររៀបចំដែនដី នគរូបនីយកម្ម យើងបានសម្រេចលទ្ធផលប្លង់គោលប្រើប្រាស់ដី ក្រុងសៀមរាប ចក្ខុវិស័យឆ្នាំ២០៣៥ និងគ្រោងនឹងបញ្ចប់ក្នុងឆ្នាំ២០២៣នេះ ចំនួន ២ស្រុកបន្ថែមទៀត។

ការអភិវឌ្ឍន៍វិស័យសំណង់ មានការរីកចំរើនគួរឱ្យកត់សំគាល់ ក្នុងនោះសំណង់តូច ធំ និងសំណង់លំនៅដ្ឋានគ្រប់ប្រភេទនៅក្នុងភូមិសាស្ត្រខេត្ត ដាក់ស្នើងគម្រោងសាងសង់ ៣៧គម្រោង ទទួលបានការអនុញ្ញាតពីក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានផ្ទៃក្រឡាសំណង់ ៥៨២ពាន់ម៉ែត្រក្រឡា ទុនវិនិយោគ ១ ១១៩លានដុល្លារអាមេរិក។ គម្រោងសាងសង់ ៣៥១គម្រោង ទទួលបានការអនុញ្ញាតពីរដ្ឋបាលខេត្ត មានផ្ទៃក្រឡាសំណង់ប្រមាណ ១លានម៉ែត្រក្រឡា ទុនវិនិយោគ ៣១០លានដុល្លារ និងគម្រោងសាងសង់ ១ ៩១៥គម្រោង មានផ្ទៃក្រឡាសំណង់ ៦១១ពាន់ម៉ែត្រក្រឡា ទុនវិនិយោគ ១៥៥លានដុល្លារអាមេរិក។

ក្រុមការងារខេត្ត បានចូលរួមជាមួយក្រុមការងារតម្រង់ទិសបានសម្របសម្រួលដោះស្រាយ ជាមួយប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់រមណីយដ្ឋានអង្គរ និងស្រង់ទិន្នន័យប្រជាពលរដ្ឋដែលស្ម័គ្រចិត្តផ្លាស់ប្តូរការរស់នៅពីតំបន់រមណីយដ្ឋានអង្គរ ទៅនៅតំបន់អភិវឌ្ឍន៍ធម្មជាតិរុនតាឯក និងតំបន់អភិវឌ្ឍន៍ពាក់ស្នែង សរុបចំនួន ៩ ៦៩៥គ្រួសារ និងបានផ្តល់ប័ណ្ណក្រីក្រ ឧបត្ថម្ភគ្រឿងឧបភោគ-បរិភោគ និងសម្ភារៈសំណង់។ ក្រុមការងារតម្រង់ទិសក៏បានសហការជាមួយកងពលធំលេខ២ និងយោធភូមិភាគទី៤ បានដឹកជញ្ជូន និងជួយរុះរើផ្ទះប្រជាពលរដ្ឋបាន ២ ០៤៧ខ្នងផ្ទះ ហើយកំពុងបន្តសម្របសម្រួលជាបន្តបន្ទាប់។ ដើម្បីផ្តល់ភាពងាយស្រួលការរស់នៅជូនបងប្អូនប្រជាពលរដ្ឋ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានចាត់មន្ត្រីជំនាញចុះវាស់វែងរៀបចំទីតាំងដីឡូត៍ផ្តល់កម្មសិទ្ធិ និងហេដ្ឋារចនាសម្ព័ន្ធ ដូចជាផ្លូវ ទឹកស្អាត អគ្គិសនី មណ្ឌលសុខភាព ផ្សារ សាលារៀន វត្តអារាម និងការផ្តល់សេវាផ្សេងតាមផែនការដែលបានគ្រោងទុក។

ជាមួយនឹងការគិតគូរពីកត្តាជីវភាពបងប្អូនប្រជានេសាទ និងប្រជាកសិករអាស្រ័យផល ឬ រស់នៅជាក់ស្តែងនៅតំបន់២ និងតំបន់៣ ដែលគ្រប់គ្រងដោយអាជ្ញាធរបឹងទន្លេសាប **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានផ្តល់គោលការណ៍ណែនាំក្រុមការងារថ្នាក់ជាតិ និងថ្នាក់ខេត្ត បានចុះសិក្សា និងលើកយោបល់សម្រាប់ការដោះស្រាយ ដែលក្នុងនោះក្រុមការងារបានចុះស្រង់ស្ថិតិប្រជាជន ទិន្នន័យការប្រើប្រាស់ជាក់ស្តែង និងបានលើកយោបល់សុំការសម្រេចពីរាជរដ្ឋាភិបាល។

**១៣-ការងារអប់រំ**

ទូទាំងខេត្តមានគ្រឹះស្ថានសិក្សាទាំងរដ្ឋ និងឯកជនសរុបចំនួន ១,៣៦៨សាលា/កន្លែង ស្មើនឹង ៧,៧១៣ថ្នាក់ សិស្ស សរុប ២៨៣,៧៦៣នាក់ ស្រី ១៤៣, ៨៣៨នាក់។ សមិទ្ធផលរយៈពេល ៥ឆ្នាំនេះ ការអប់រំសម្រេចបាននូវវឌ្ឍនភាពការងារជាច្រើនរួមមាន៖

- សិស្សមត្តេយ្យសិក្សា ៣៣ ០៣៨នាក់ កើន ៨ ០៣៩នាក់ ធៀបនឹងឆ្នាំសិក្សា ២០១៧-២០១៨ មានសាលាមត្តេយ្យទូទាំងខេត្តចំនួន ៦៥៣កន្លែង កើន៤៣កន្លែង ក្នុងនោះ សាលាមត្តេយ្យសិក្សាជាច់ ២៧កន្លែង សាលាមត្តេយ្យសិក្សាក្នុងបឋម ៤៣៦កន្លែង និងសាលាមត្តេយ្យសិក្សាសហគមន៍ ១៩០កន្លែង។
- សិស្សបឋមសិក្សា ១៧១ ១៥៤នាក់ កើន ២ ៥៩៥នាក់ ធៀបនឹងឆ្នាំសិក្សា ២០១៧-២០២១៨ មានសាលាបឋមសិក្សាទូទាំងខេត្តចំនួន ៥៦៨កន្លែង កើន ៣២កន្លែង ក្នុងនោះសាលាបឋមសិក្សារដ្ឋ ៥២២កន្លែង និងសាលាបឋមសិក្សាឯកជន ៤៦កន្លែង។
- សិស្សមធ្យមសិក្សាចំណេះទូទៅ ៨៩ ៤១៣នាក់ កើន ៤៣ ៨៩៥នាក់ ធៀបនឹងឆ្នាំសិក្សា ២០១៧-២០១៨ មានសាលាបឋមសិក្សាទូទាំងខេត្ត ១៤៧កន្លែង កើន ៩កន្លែង ក្នុងនោះសាលា-មធ្យមសិក្សាចំណេះទូទៅរដ្ឋ ១២៤កន្លែង និងសាលាមធ្យមសិក្សាឯកជន ២៣កន្លែង។
- លទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សា បឋមភូមិ ក្នុងរង្វង់ ៩៥% និងលទ្ធផលប្រឡង-សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ក្នុងរង្វង់ ៧៥% ហើយសិស្សទទួលបាននិទ្ទេស A ក៏ទទួលបានអត្រាខ្ពស់ផងដែរ។

IV-**ទិសដៅ**

ឆ្នាំ២០២៣នេះ រដ្ឋបាលខេត្ត មន្ទីរ អង្គភាពជុំវិញខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ត្រូវមានឆន្ទៈប្តេជ្ញាខ្ពស់ចំពោះបេសកកម្មរបស់ខ្លួន ដើម្បីបន្តអនុវត្តភារកិច្ចការងារដែលនៅសេសសល់ពី

ឆ្នាំ២០២២ផង និងកិច្ចការនានាក្នុងឆ្នាំ២០២៣ ស្ថិតក្នុងក្របខណ្ឌនៃផែនការអភិវឌ្ឍខេត្ត ដើម្បីសម្រេចបាននូវសមិទ្ធផលប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

ពិតណាស់ទិសដៅការងារឆ្នាំ២០២៣នេះ រដ្ឋបាលខេត្តបានធ្វើការប៉ាន់ប្រមាណប្រកបដោយចក្ខុវិស័យទូលំទូលាយ ក្នុងការកំណត់នូវយុទ្ធសាស្ត្រក្នុងដំណាក់កាលនីមួយៗ និងស្របតាមសភាព-ការណ៍ជាក់ស្តែងនៃការវិវត្តនូវស្ថានភាពសង្គម-សេដ្ឋកិច្ច ដើម្បីឆ្លើយតបនឹងសំណូមពរចាំបាច់របស់ប្រជាពលរដ្ឋ និងរក្សាបាននូវស្ថិរភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ បរិស្ថានធម្មជាតិ វប្បធម៌ សីលធម៌សង្គម សេចក្តីថ្លៃថ្នូរ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ផ្តើមចេញពីកត្តាគន្លឹះទាំងនេះ ខ្ញុំសូមលើកឡើងនូវការងារអាទិភាពមួយចំនួនរបស់រដ្ឋបាលខេត្តដូចខាងក្រោម ៖

១- បន្តពង្រឹងការអនុវត្តគោលនយោបាយ **"ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព"** ផ្សព្វផ្សាយលក្ខណៈសម្បត្តិ ៩យ៉ាង នៃភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ជំរុញចលនាប្រជាជនចូលរួម និងកសាងកម្លាំងប្រជាការពារ សាងសង់ប៉ុស្តិ៍ប្រជាការពារ សម្រាប់ចូលរួមសហប្រតិបត្តិការបង្ក្រាបបទល្មើសគ្រប់ប្រភេទ និងការរៀបចំសណ្តាប់ធ្នាប់សាធារណៈ

២- គ្រប់មន្ទីរ អង្គភាពត្រូវរួមសហការឱ្យបានកាន់តែសកម្ម និងមានប្រសិទ្ធភាព និងចាត់វិធានការបើកកិច្ចប្រតិបត្តិការបង្ការ បង្ក្រាបបទល្មើសគ្រប់ប្រភេទរួមមាន បទល្មើសផ្លូវភេទ ការជួញដូរស្រ្តី និងកុមារ គ្រឿងញៀន ល្បែងស៊ីសង បទល្មើសបច្ចេកវិទ្យា បទល្មើសសេដ្ឋកិច្ច ពិសេសផលិតផលក្លែងក្លាយមានសារធាតុគីមីហាមឃាត់គ្រប់ប្រភេ និងឱសថក្លែងក្លាយ។

៣- អប់រំ ផ្សព្វផ្សាយ ពង្រឹងការទប់ស្កាត់ និងចាត់វិធានការតាមផ្លូវច្បាប់ចំពោះការបំផ្លាញធនធានធម្មជាតិ និងទន្ទ្រានកាន់កាប់ដីព្រៃឈើក្នុងតំបន់ការពារធម្មជាតិ ព្រៃសហគមន៍ ដែនអភិរក្ស និងរបៀងជីវៈចម្រុះ លើកផែនការការងារសម្រាប់ការបោះបង្គោលព្រំប្រទល់ និងលើកស្លាកសញ្ញាហាមឃាត់ ឬសម្គាល់តំបន់ទាំងនោះ។

៤- ពង្រឹងការផ្តល់សេវារដ្ឋបាលតាមរយៈច្រកចេញចូលតែមួយនៅថ្នាក់ខេត្ត ក្រុង ស្រុក ឱ្យបានឆាប់រហ័ស ធានាបានតម្លាភាព និងដោះស្រាយ ឬលើកសំណូមពរដោះស្រាយចំពោះ សេវាមានលក្ខណៈស្មុគស្មាញ និងការអនុវត្តការផ្តល់សេវាតាមយន្តការច្រកចេញចូលតែមួយនៅថ្នាក់ឃុំសង្កាត់។

៥- ពន្លឿនការដោះស្រាយពាក្យបណ្តឹងនានារបស់ប្រជាពលរដ្ឋ ដោយរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ដោយត្រូវពិនិត្យ ដោះស្រាយតាមសមត្ថកិច្ច និងយន្តការដែលមានស្រាប់ ពិសេសបន្តប្រើយន្តការដោះស្រាយទំនាស់ដីធ្លីក្រៅប្រព័ន្ធតុលាការ។

៦- ស្នើសុំការគាំទ្របច្ចេកទេសក្នុងការរៀបចំប្លង់គោលដីធ្លីស្រុកតាមបណ្តោយផ្លូវជាតិលេខ៦។ ដោយឡែកស្រុកដទៃទៀត ត្រូវយកចិត្តទុកដាក់រៀបចំទីប្រជុំជនស្រុក ឃុំ ឱ្យមានរបៀបរៀបរយ និងប្រកបទៅដោយទស្សនៈវិស័យទីប្រជុំជន។

៧- ពង្រឹងការអនុវត្តមុខងាររបស់រដ្ឋបាលក្រុង ស្រុក លើការគ្រប់គ្រងសំរាម សំណល់រឹង ទីប្រជុំជន និងគ្រប់គ្រងប្រព័ន្ធលូ ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ បន្តកិច្ចសហការជាមួយដៃគូអភិវឌ្ឍ និងវិស័យឯកជនក្នុងការគ្រប់គ្រងសំរាម។

៨- ពង្រីកសក្តានុពលទេសចរណ៍ គុណភាពផលិតផល និងសេវាកម្មទេសចរណ៍ អភិវឌ្ឍធនធានមនុស្សផ្នែកជំនាញវិជ្ជាជីវៈទេសចរណ៍លើការងារបដិសណ្ឋារកិច្ច សេវាកម្មដឹកជញ្ជូន និងសេវាមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងរៀបចំផែនការអភិវឌ្ឍទេសចណ៍ទៅតាមតំបន់គោលដៅទេសចរណ៍ក្នុងក្រុង និងតាមបណ្តាស្រុក។ ជាមួយគ្នានោះ ខេត្តនឹងអនុវត្តសកម្មភាពនានាឆ្លើយតបទៅនឹងស្ថានភាព នៃការធ្លាក់ភ្ញៀវទេសចរស្របតាមវិធានការនានារបស់រាជរដ្ឋាភិបាល។

៩- បន្តជំរុញការដាំដុះ ការចិញ្ចឹមសត្វ វារីវប្បកម្ម ផ្សព្វផ្សាយអំពីបច្ចេកទេសកសិកម្ម ជំរុញការងារបង្កបង្កើនផលិតផលកសិកម្មដែលមានសុវត្ថិភាព និងសរីរាង្គ ជំរុញចលនាភូមិមួយផលិតផលមួយតាមរយៈការចងក្រងផលិតផលសក្តានុពល រៀបចំពិព័រណ៌ផលិតផល ចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គាំទ្រការកែច្នៃ វេចខ្ចប់ និងទីផ្សារ ក្នុងន័យបង្កើត ប្រាក់ចំណូលគ្រួសារ កាត់បន្ថយចំណាកស្រុក ការនាំចូល និងបំពេញតម្រូវការក្នុងស្រុក និងការនាំចេញ។

ដើម្បីសម្រេចបាននូវសមិទ្ធផល ដូចបានរៀបរាប់ខាងលើ ការថែរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ស្ថេរភាពនយោបាយ និងការថែរក្សាសន្តិភាព គឺជាកត្តាគន្លឹះមួយ ដែលរដ្ឋបាលខេត្តសៀមរាប បានខិតខំប្រឹងប្រែងបំពេញតួនាទី ភារកិច្ចរបស់ខ្លួន ប្រកបដោយការទទួលខុសត្រូវ និងគោរពតាមអភិក្រមទាំង **៥ របស់** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី **គឺ** ងូតទឹក ដុះក្អែល ឆ្លុះកញ្ចក់ ព្យាបាល និងវះកាត់។